ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

# គោលការណ៍ណែនាំសម្រាប់អ្នកសម្របសម្រួល ស្តីពី សាលារៀនស្រែកសិករ









**រៀបចំដោយ :** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

**ឧបត្ថម្ភដោយៈ** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD)

**ភ្នំពេញ ខែ កក្កដា ឆ្នាំ ២០១៧**

# មាតិកា


អារម្ភកថា....4
សេចក្តីផ្តើម....5
ជំពូកទី ១....7
គោលគំនិត លក្ខណៈ និងគោលការណ៍សាលារៀនស្រែកសិករ....7
១. ប្រវត្តិសាលារៀនស្រែកសិករ....7
២.គោលគំនិត និងទស្សនៈទានសាលារៀនស្រែកសិករ....7
២.១. និយមន័យសាលារៀនស្រែកសិករ....7
២.២. គោលបំណងសាលារៀនស្រែកសិករ....8
៣. គោលការណ៍សាលារៀនស្រែកសិករ....9
៤. លក្ខណៈសាលារៀនស្រែកសិករ....11
ជំពូកទី ២ ការរៀបចំ និងដំណើរការសាលារៀនស្រែកសិករ....14
១.១. ការបណ្តុះបណ្តាលគ្រូបង្គោល....14
១.២. ការកំណត់ប្រធានបទ ទីកន្លែង និងកសិករចូលរួម....15
១.៣. ការរៀបចំធ្វើស្រែបង្ហាញ....16
១.៤. ការរៀបចំដំណើរការវគ្គសាលារៀនស្រែកសិករមួយ....29
១.៥. បិទវគ្គ និងធ្វើទិវាស្រែ....31
១.៦. ការដំណើរការសាលារៀនស្រែកសិករដោយកសិករគំរូ....32
១.៧. ការតាមដានបន្តរបស់អ្នកសម្របសម្រួល....32
ជំពូកទី ៣ គោលគំនិត វិធីសាស្ត្រ និងឧបករណ៍សំខាន់ៗប្រើប្រាស់ និងវិធីសាស្ត្រសម្របសម្រួល ក្នុងសាលារៀនស្រែកសិករ....33
១. គោលគំនិត វិធីសាស្ត្រ និងឧបករណ៍សំខាន់ៗប្រើប្រាស់ ក្នុងសាលារៀន ស្រែកសិករ....33
១.១. ប្រព័ន្ធអេកូឡូស៊ី (ប្រព័ន្ធបរិស្ថាន)....33
១. ២. ទស្សនៈនេះជាអ្វី? នោះជាអ្វី?....34
១. ៣. ការវិភាគក្បែត្រ-បរិស្ថាន....36
២. វិធីសាស្ត្រសម្របសម្រួល ក្នុងសាលារៀនស្រែកសិករ....39
២.១. ការផ្តល់មេរៀន និងការបកស្រាយបង្ហាញ....39
២.២. ការធ្វើបង្ហាញជាក់ស្តែង....40

២.៣. ការពិភាក្សាក្រុមតូច ........................................................................................................................ 41
២.៤. ការពិភាក្សាក្រុមធំ ឬពិភាក្សារួម ................................................................................................... 42
២.៥. ការបំផុសគំនិត ........................................................................................................................... 42
២.៦. ការចុះពិនិត្យ និងសង្កេតផ្ទាល់ .................................................................................................... 43
២.៧. ការលើកករណីសិក្សា .................................................................................................................. 44
២.៨. ការរៀបចំការសំដែងតួ ឬ សំដែងសកម្មភាព (Role Play) ................................................................ 45
២.៩. ល្បែងស្ថាបនាក្រុម (Team Building Exercise) ............................................................................ 46
២.១០. ការបង្កើតល្បែងកំសាន្ត (Ice Breaker) ....................................................................................... 46
២.១១. ការសន្ទនា និងជជែក..................................................................................................................... 47
២.១២. សំណួរ និងចម្លើយ ....................................................................................................................... 47
២.១៣. ការផ្តល់មេរៀនពិសេសខ្លីៗ ......................................................................................................... 49
២.១៤. ការប្រើឯកសារសោតទស្សន៍ ឬប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម.................................................... 49
**ជំពូកទី ៤ ការរៀបចំប្លង់មេរៀនក្នុងសាលារៀនស្រែកសិករមួយ ..................................................... 51**
១. ការរៀបចំប្លង់មេរៀនសម្រាប់សាលារៀនស្រែកសិករ ........................................................................... 51
២. គំរូប្លង់ការរៀបចំការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ................................................................................ 52
៣. គំរូសកម្មភាពសាលារៀនស្រែកសិករក្នុងសប្តាហ៍នីមួយៗ..................................................................... 54
៣.១. សប្តាហ៍ទី១ : ការបើកវគ្គជាផ្លូវការ និងណែនាំពីសាលារៀនស្រែកសិករ ............................................ 54
៣.២. សប្តាហ៍ទី២: ទៅសប្តាហ៍បន្តបន្ទាប់.................................................................................................. 56
៣.៣. សប្តាហ៍ទី ...... ការគ្រប់គ្រងអាជីវកម្មកសិកម្ម និងទីផ្សារ ................................................................ 56
៣.៤. សប្តាហ៍ទី.......ការវិភាគចំណូល ចំណាយក្នុងរបរអាជីវកម្មកសិកម្ម.................................................. 60
៣.៥. សប្តាហ៍ទី.......ការយល់ដឹងអំពីដំណើរការទីផ្សារ និងទីផ្សារ ............................................................. 23
៣.៦. សប្តាហ៍ទី.......ការរៀបចំគម្រោងអាជីវកម្មកសិកម្មមួយក្នុងកសិដ្ឋាន................................................. 27
**ជំពូកទី ៥ ការពិនិត្យតាមដាន និងវាយតម្លៃ និងកត់ត្រាសាលារៀនស្រែកសិករ ................................ 33**
**ឯកសារយោង ..................................................................................................................................... 38**

# អារម្ភកថា

អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំគោលការណ៍ណែនាំពីសាលារៀនស្រែកសិករ សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលអ្នកសម្របសម្រួលក្នុងសាលារៀនស្រែកសិករនិងការផ្សព្វផ្សាយ បច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តល្អថ្មីៗ ពាក់ព័ន្ធនឹងកសិកម្មដែលធន់ នឹងការប្រែប្រួលអាកាសធាតុ ធ្វើមុខរបរអាជីវកម្ម កសិកម្ម ការចាត់ចែង និងគ្រប់គ្រងក្រុមកសិករ និងដើម្បីលើកកម្ពស់ ផលិតភាព គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ គោលការណ៍ណែនាំ នេះក៏អាចប្រើប្រាស់បានសម្រាប់បណ្តុះបណ្តាលគ្រូបង្គោលផ្សព្វផ្សាយអ្នកបច្ចេកទេស កសិកម្ម និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មនានានៅមូលដ្ឋាន។

គោលការណ៍ណែនាំនេះរៀបចំឡើង ក្នុងក្របខ័ណ្ឌឯកសារបណ្តុះបណ្តាល និងផ្សព្វផ្សាយដោយមានការចូលរួមសម្រាប់អនុវត្តការផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យា ដល់កសិករ និងប្រតិបត្តិករនានាដែលពាក់ព័ន្ធនឹងកម្មវិធី ផ្សព្វផ្សាយកសិកម្មនានាក្នុងបរិបទតម្រូវការទីផ្សារ និងការប្រែប្រួលអាកាសធាតុ។ គោលការណ៍ណែនាំនេះបានរៀបចំ ឡើងដោយផ្អែកលើបទពិសោធន៍នានាពីសាលារៀនស្រែកសិករនានានៅកម្ពុជា មានសាលារៀនស្រែកសិករពីវិធានការណ៍ចម្រុះថែទាំដំណាំលើស្រូវ បន្លែ សាលារៀនស្រែកសិករពីវិធាន-ការណ៍ចម្រុះគ្រប់គ្រងដីជាតិដី និងការអភិវឌ្ឍបច្ចេកទេសដោយមានការចូលរួមនានារបស់កម្មវិធីផ្សព្វផ្សាយ កសិកម្មនៅតាមបណ្តាភូមិឃុំនានានៅកម្ពុជា។

គោលការណ៍ណែនាំនេះធ្វើឡើង ដោយធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយអ្នកផ្សព្វផ្សាយកសិកម្ម អ្នកជំនាញ បច្ចេកទេស អ្នកឯកទេស និងអ្នកពាក់ព័ន្ធមកពីស្ថាប័ន និងអង្គភាពផ្សព្វផ្សាយកសិកម្ម អង្គភាពជំនាញបច្ចេកទេសនានា ។

គោលការណ៍ណែនាំនេះ ជាឯកសារគ្រឹះដែលពិពណ៌នាពីបច្ចេកទេស វិធីសាស្ត្រ និងនិតិវិធីរៀបចំ និងសម្របសម្រួលក្នុងសាលារៀនស្រែកសិករ ដើម្បីជួយដល់មន្ត្រីផ្សព្វផ្សាយ មន្ត្រីបច្ចេកទេស មន្ត្រីផ្សព្វផ្សាយកសិកម្ម ស្រុកនិងភ្នាក់ងារផ្សព្វផ្សាយនៅមូលដ្ឋាននានា យកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាលនិងផ្សព្វផ្សាយ បច្ចេកទេស ដើម្បីផ្ទេរចំណេះដឹង ព័ត៌មាននិងបច្ចេកវិទ្យាកសិកម្មដល់ប្រជាកសិករនិងប្រតិបត្តិករក្នុងកម្មវិធីផ្សព្វផ្សាយកសិកម្ម និងកម្មវិធីនិងគម្រោងអភិវឌ្ឍកសិកម្មនានានៅកម្ពុជា។

អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សូមដាក់ចេញនូវគោលការណ៍ណែនាំពីសាលារៀនស្រែកសិករនេះ ដែលជាឯកសារគ្រឹះសម្រាប់មន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-រាជធានី ក្រុង ស្រុក ខណ្ឌ អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទ។

**រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧**

**អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម**

# សេចក្តីផ្តើម

ការប្រែប្រួលអាកាសធាតុជាបញ្ហាសាកល ដែលកើតមានឡើងយ៉ាងច្បាស់ និងមានឥទ្ធិពលលើវិស័យកសិកម្ម ធនធានទឹក ជាពិសេសផលិតកម្មស្បៀងអាហារនៅក្នុងបណ្តាប្រទេសមួយចំនួនលើសាកលលោក ដោយការកើនឡើងកំដៅ គ្រោះទឹកជំនន់ រាំងស្ងួត ភ្លៀងមិនទៀងទាត់ ការកើនឡើងកម្ពស់ទឹកសមុទ្រហូរនិងជ្រាបចូលដីស្រែ ចំការការផ្ទុះនូវសត្វល្អិត ជម្ងឺ ។ល។ ព្រះរាជាណាចក្រកម្ពុជាបានទទួលរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុរួចមកហើយ ដោយមានការកើតឡើង ពីភាពមិនប្រក្រតីនៃអាកាសធាតុ ដូចជា មានព្រឹត្តិការណ៍ទឹកជំនន់ ភាពរាំងស្ងួត សត្វល្អិត និងជម្ងឺបំផ្លាញ ខ្យល់ព្យុះ ការកើនឡើងកម្ពស់ទឹកសមុទ្រ ដែលបណ្តាលឲ្យមាន ផលិតភាពកសិកម្មទាប និងមានផលប៉ះពាល់ដល់សន្តិសុខស្បៀង និងភាពក្រីក្រ។ ប្រទេសកម្ពុជាមានឆ្នេរសមុទ្រវែងរហូតដល់ ៤៣៥គីឡូម៉ែត្រ និងមានរយៈកម្ពស់ទាប ផ្ទៃដីវាលទំនាប តាមអាងទន្លេគង្គក្រោម តំបន់ទន្លេសាប ហើយមានប្រជាពលរដ្ឋរស់នៅច្រើន និងមានសកម្មភាពសេដ្ឋកិច្ចពឹងផ្អែកលើមុខរបរកសិកម្ម ធនធានជលផល ព្រៃឈើ និងធនធានធម្មជាតិ ហើយមានផ្ទៃដីស្រែទំនាបពឹងដោយរបបទឹកភ្លៀង ប្រមាណជាង ២.៥លានហិកតា។

វិស័យកសិកម្មបានទទួលរងពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ តែវិស័យកសិកម្មក៏បានចូលរួមចំណែក យ៉ាងសំខាន់ក្នុងការបន្សាំ បង្កើនភាពធន់ និងបន្ធូរបន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ ដើម្បីធានាប្រព័ន្ធផលិត ចែកចាយ និងផ្គត់ផ្គង់ស្បៀង មាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមរយៈការប្រើប្រាស់ បច្ចេកវិទ្យា បច្ចេកទេសនិងការអនុវត្តកសិកម្មល្អនានាដូចជា ពូជដំណាំធន់ ពូជសត្វ ការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ ប្រពលវប្បកម្មដំណាំ សត្វ ច្បារដំណាំគ្រួសារ កសិកម្មអភិរក្ស ប្រព័ន្ធដំណាំស្បៀង និងថាមពលចម្រុះ ប្រព័ន្ធគ្រប់គ្រងព្រៃឈើ ដី និងទឹកមាននិរន្តរភាព និងកសិរុក្ខកម្ម។ល។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ជាកម្មវិធីជាតិមួយមានគោលបំណងកាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់របស់គ្រួសារកសិករក្រីក្រនិងងាយរងគ្រោះខ្នាតតូចនៅកម្ពុជា។ កម្មវិធីនេះមានគោលដៅ កែលំអសេវាផ្សព្វផ្សាយកសិកម្មដល់កសិករខ្នាតតូចនៅកម្ពុជា និងទទួលបានការលើកកម្ពស់គំរូមួយសម្រាប់សេវាកសិកម្ម ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច តាមរយៈបង្កើនប្រាក់ចំណូល និងភាពធន់នឹងអាកាសធាតុក្នុងមុខរបរកសិកម្ម។

គោលការណ៍ណែនាំសម្រាប់សម្របសម្រួលសាលារៀនស្រែកសិករនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់គោលការណ៍ណែនាំដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ឱ្យមានសមត្ថភាពសម្រាប់ ដឹកនាំការពិភាក្សា និងសម្របសម្រួលក្នុងការចងក្រុមកសិករសិក្សា ការវាយតម្លៃតម្រូវការរបស់កសិករ និងដំណើរការសាលារៀនស្រែកសិករលើអនុវត្តបច្ចេកទេសកសិកម្មថ្មី ការធ្វើមុខរបរអាជីវកម្មកសិកម្ម និងការលើកកម្ពស់ការចាត់ចែង និងគ្រប់គ្រងក្រុកសិករ ដើម្បីលើកកម្ពស់ផលិតភាព គុណភាព

និងសុវត្ថិភាពផលិតផលកសិកម្ម បង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុនិងបង្កើនប្រាក់ចំណូលគ្រួសារ។

តាមរយៈឧបករណ៍ វិធីសាស្ត្រ និងលំហាត់នានានៃឯកសារណែនាំនេះ ដូចជាការពិព័ណ៌នា និងពិភាក្សា ពីការរៀបចំក្រុមកសិករសិក្សា វិភាគបញ្ហាការប្រែប្រួលអាកាសធាតុ និងការអនុវត្តបច្ចេកវិទ្យា ការអនុវត្តបច្ចេកទេស ការអនុវត្តនូវនវានុវត្តន៍ថ្មីៗ និងការគ្រប់គ្រងរបរអាជីវកម្មកសិកម្ម ប្រធានបទនៃការប្រែប្រួលអាកាសធាតុ ជាពិសេសផលប៉ះពាល់និងសកម្មភាពនានាដែលកសិករអាច អនុវត្តដើម្បីបន្ថយភាពងាយរងគ្រោះ និងបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិនានា។

អគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ជាអ្នកផ្តល់ការបណ្តុះបណ្តាលក្នុងការប្រើប្រាស់គោលការណ៍ណែនាំនេះដល់អ្នកផ្សព្វផ្សាយកសិកម្មនានារួមមាន មន្ត្រីផ្សព្វផ្សាយកសិកម្មរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋាននានា និងជាអ្នកត្រួតពិនិត្យ និងវាយតម្លៃគុណភាពដំណើរសាលារៀនស្រែកសិករ និងស្រែបង្ហាញ ហើយធ្វើការវិភាគ និងវាយតម្លៃពីដំណើរការអនុវត្តសៀវភៅណែនាំនេះ។

### តើអ្នកណាប្រើប្រាស់ឯកសារគោលការណ៍ណែនាំនេះ?

គោលការណ៍ណែនាំនេះអាចប្រើប្រាស់បានដោយមន្ត្រីបច្ចេកទេស មន្ត្រីផ្សព្វផ្សាយ ភ្នាក់ងារប្រតិបត្តិ និងអ្នកផ្សព្វផ្សាយនៅមូលដ្ឋាន សម្រាប់ដឹកនាំ សម្របសម្រួលក្នុងសាលារៀនស្រែកសិករ បណ្តុះបណ្តាលគ្រូបង្គោល កសិករ និងធ្វើបង្ហាញបច្ចេកទេស ការតាមដានវាយតម្លៃកម្មវិធី និងសកម្មភាពសាលារៀនស្រែកសិករ។ អ្នកបច្ចេកទេស និងអ្នកផ្សព្វផ្សាយកសិកម្មប្រើប្រាស់ឯកសារនេះ សម្រាប់បង្កើត និងរៀបចំកម្មវិធីផ្សព្វផ្សាយ កម្មវិធីបណ្តុះបណ្តាលកសិករ និងផែនការអភិវឌ្ឍភូមិ ឃុំ។ល។ ចំពោះមន្ត្រីផ្សព្វផ្សាយវិញឯកសារនេះជួយផ្តល់ជាមេរៀននិងជំនាញដោយផ្ទាល់ សម្រាប់អនុវត្តក្នុងការបណ្តុះបណ្តាលកសិករ ។

### សារៈសំខាន់គោលការណ៍ណែនាំសាលារៀនស្រែកសិករមាន៖

- ជួយដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយឱ្យអនុវត្តសកម្មភាពសាលារៀនស្រែកសិករបានរលូនល្អទៅតាមពេលវេលា
- រៀបចំ និងអនុវត្ត សកម្មភាពនីមួយៗទទួលលទ្ធផលជាក់លាក់ និងច្បាស់លាស់
- ធានាបានឱ្យកសិករយល់ដឹងពីគោលបំណងនៃសកម្មភាពនីមួយៗ
- ធានាបាន ទាំងអ្នកសម្របសម្រួល និងកសិករស្គាល់តួនាទីរបស់ខ្លួន
- អ្នកសម្របសម្រួលរៀបចំបានល្អគ្រប់ប្រធានបទ និងបច្ចេកទេសបណ្តុះបណ្តាល
- ធានាឱ្យមានធនធាន និងសម្ភារចាំបាច់គ្រប់គ្រាន់សម្រាប់សាលារៀនស្រែកសិករ។

# ជំពូកទី ១

# គោលគំនិត លក្ខណៈ និងគោលការណ៍សាលារៀនស្រែកសិករ

## ១. ប្រវត្តិសាលារៀនស្រែកសិករ

វិធីសាស្ត្រសាលារៀនស្រែកសិករ បានបង្កើតឡើងដោយគម្រោងរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (អង្គការហ្វាវ) នៅតំបន់អាស៊ី-អាគ្នេយ៍ជាមួយកសិករដាំដំណាំស្រូវ ដើម្បីឱ្យកសិករស្រាវជ្រាវ និងសិក្សា ដោយខ្លួនគាត់ផ្ទាល់។ ពាក្យសាលារៀនស្រែកសិករមកពីពាក្យឥណ្ឌូនេស៊ី (Indonesian Sekolar Lampangan) មានន័យថា **សាលារៀនស្រែ**។ សាលារៀនស្រែកសិករដំបូងបានបង្កើតឡើងឆ្នាំ១៩៨៩ នៅភាគកណ្ដាលនៃកោះជ្វា (Central Java) ប្រទេសឥណ្ឌូនេស៊ីដោយគម្រោងសាកល្បងរបស់អង្គការហ្វាវជួយកម្មវិធីជាតិស្ដីពី **"វិធានការណ៍ ចម្រុះការពារដំណាំ"** របស់ឥណ្ឌូនេស៊ី។ ក្រោយមកសាលារៀនស្រែកសិករបានទទួលយកមកប្រើ និងពង្រីកនៅក្នុងប្រទេសក្នុងតំបន់អាស៊ីមានប្រទេសហ្វីលីពីន វៀតណាម កម្ពុជា ថៃ ប្រទេសចិន តាមរយៈកម្មវិធី IPM កម្មវិធី FARM (FAO/UNDP) ក្នុងគម្រោងវិធានការណ៍ចម្រុះគ្រប់គ្រងដីជាតិដី និងកម្មវិធីសន្តិសុខស្បៀង ហើយបានពង្រីក ដល់ប្រទេសមួយចំនួននៅទ្វីបអាហ្វ្រិច និងតំបន់អាមេរិកឡាទីន។

## ២.គោលគំនិត និងទស្សនៈទានសាលារៀនស្រែកសិករ

### ២.១. និយមន័យសាលារៀនស្រែកសិករ

សាលារៀនស្រែកសិករ គឺជាវេទិកា និងសាលារៀនគ្មានជញ្ជាំង សម្រាប់បង្កើនសមត្ថភាពសម្រេចចិត្តរបស់កសិករ និងសហគមន៍កសិករប្រមូលផ្ដុំនូវបច្ចេកទេសនៅមូលដ្ឋាននិងបច្ចេកទេសថ្មីៗសមស្រប។ សាលារៀនស្រែកសិករជាឧបករណ៍និងវិធីសាស្ត្រសម្រាប់ផ្សព្វផ្សាយបច្ចេកទេសដែលផ្ដល់អាទិភាព ឱ្យកសិករ ជ្រើសរើសទៅប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម ដោយផ្អែកលើវិធីសាស្ត្រសិក្សាស្រាវជ្រាវរុករកដោយផ្ទាល់។

សាលារៀនស្រែកសិករក៏ជាឧបករណ៍មួយរបស់កម្មវិធីផ្សព្វផ្សាយកសិកម្ម និងគម្រោងអភិវឌ្ឍសហគមន៍ និងកសិកម្មចម្រុះនានានៅកម្ពុជាសម្រាប់អនុវត្តការអប់រំ ការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលដោយមានការចូលរួមពីក្រុមពហុជំនាញរួមមាន៖ ផ្នែកដាំដុះដំណាំមាន ការគ្រប់គ្រងដំណាំ ការគ្រប់គ្រងដីជាតិដី វិធានការណ៍ចម្រុះការពារដំណាំ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការគ្រប់គ្រងទឹក យេនឌ័រ អាហាររូបត្ថម្ភ និងការអប់រំពីសុខភាព-អនាម័យ ការគ្រប់គ្រងកសិដ្ឋាន (អាជីវកម្មកសិកម្ម និងសហគ្រាសកសិកម្ម) និងឥណទាន។ល។